# ការអធិស្ឋានជាមួយស្សារ៉ា

ដោយ ស្សេរី ហ្គារីន

ផ្អែកទៅលើដំណើររឿងពិត

នាថ្ងៃមួយក្នុងរដូវក្តៅ រីសី និង ឆេយ៉េនី បាន អញ្ជើញ ស្សារ៉ាមកលេងជាមួយគ្នា ។ ម៉ាក់ បានធ្វើអាហារសម្រន់ ។ ក្មេងស្រីៗអង្គុយញ៉ាំអាហារ នៅឯតុបាយ ។

ម៉ាក់បានចិតស្វាយជាចំណិតៗដែលបានបេះមកពីដើម ស្វាយរបស់ពួកគេ ។ គាត់បានដាក់ចំណិតផ្លែប៉ោម និង ទំពាំងបាយជូរលើចាន ។ រីសី បានមើលទៅផ្លែឈើដ៏ ឆ្ងុយឆ្ងាញ់ទាំងនោះ ។ នាងបានចាំថាត្រូវអធិស្ឋានពីមុនញ៉ាំ អាហារសម្រន់របស់នាង ។ នាងបានសួរស្សារ៉ាថា « តើឯង អធិស្ឋាននៅផ្ទះរបស់ឯងដែរឬទេ ? »

« តើការអធិស្ឋានជាអ្វីទៅ ? » ស្សារ៉ាបានសួរ ។

ឆេយ៉េនី បាននិយាយថា « គេធ្វើដូចនេះ » ។ នាង បានឱបដៃ ហើយឱនក្បាល ។ នាងបានអធិស្ឋាន ប្រសិទ្ធពរអាហារ ។ ពេលនាងអធិស្ឋានចប់ នាងបាន និយាយថា « យល់ហើយឬនៅ ? គេធ្វើបែបហ្នឹង ។ ងាយស្រួលណាស់ ! »

ស្សារ៉ាបាននិយាយថា « យើងពុំធ្វើបែបនេះនៅផ្ទះរបស់ យើងទេឡើយ ។ យើងញ៉ាំវាតែម្តង » ។

រីសី ពុំធ្លាប់គិតអំពីការ *មិន* អធិស្ឋានឡើយ ។ នាងបាន និយាយថា « ម៉ាក់ តើយើងអាចឈប់អធិស្ឋានបានទេ ? »

ម៉ាក់បានញញឹម នៅពេលគាត់កាន់កែវទឹកកកមកកាន់តុ បាយ ។ « យើងចូលចិត្តថ្លែងអំណរគុណចំពោះព្រះវរបិតាសួគ៌ សម្រាប់អ្វីៗដែលទ្រង់បានប្រទានឲ្យយើង ។ យើងនឹងបន្ត អធិស្ឋានទៀត ។ ប៉ុន្តែវាមិនជាបញ្ហានោះទេ ប្រសិនបើមនុស្ស ផ្សេងទៀតមិនអធិស្ឋាននោះ » ។

រីសីបានដឹងថា ម៉ាក់និយាយត្រូវ ។ នាង *មាន* ក្តីរីករាយ ពេលគ្រួសាររបស់នាងអធិស្ឋាន ។ ប្រហែលជាការអធិស្ឋាន ធ្វើឲ្យស្សារ៉ារីករាយផងដែរ ។ នាងបាននិយាយទៅស្សារ៉ា ថា « ឯងអាចសាកល្បងអធិស្ឋានបាន » ។ « ការអធិស្ឋាន ជារឿងល្អណាស់ » ។

ឆេយ៉េនី បាននិយាយថា « ខ្ញុំចូលចិត្តពេលយើង អធិស្ឋាន » ។« វាធ្វើឲ្យខ្ញុំមានអារម្មណ៍ថា មានស្នាម ញញឹមមួយគ្របដណ្តប់លើពេញរូបកាយខ្ញុំ » ។

ស្សារ៉ាបានញញឹម ។ នាងបាននិយាយ ដោយញ៉ាំស្វាយ មួយចំណិតផងដែរថា « ខ្ញុំប្រហែលជាសាកល្បងធ្វើវា » ។

រីសី និង ឆេយ៉េនី សប្បាយចិត្ត ដោយសារពួកគេអាច ប្រាប់មិត្តភក្តិរបស់ខ្លួនអំពីការអធិស្ឋាន ។ ពួកគេទាំងអស់ គ្នាបានញ៉ាំអាហារសម្រន់ទាំងអស់ ហើយរត់ទៅលេងឆ្ងា ខាងក្រោយផ្ទះ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ឃ្វីនស៍ឡិន ប្រទេស អូស្ត្រាលី ។*

រចនារូបភាពដោយ គីធើរ ប្រ៊ាន់ស៊ីស/MB ARTISTS

